ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

មិថុនា ២០០៦ / June 2006

អ៊ុច ច័ន្ទតារានី / **Ouch Chandarany**

ប៉ុន ដូរីណា / **Pon Dorina**

ហ៊ីង វុត្ថា / **Hing Vutha**

ភឹម រុនស៊ីណារិទ្ធិ / **Phim Runsinarith**

បកប្រែដោយៈ **យូ សិទ្ធីរិទ្ធ និង យេន សុផានី**

**ភ្នំពេញ កម្ពុជា**

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅខែមករា-កុម្ភៈ ២00៦ ការអនុមតិគំរោងវិនិយោគឯកជនគិតជាទ្រព្យសកម្មជាប់លាប់ មាន ២១៦លានដុល្លារ ឬ ៥២% ទាបជាងរយៈពេលដូចគ្នាឆ្នាំមុន ។ វិនិយោគក្នុងវិស័យឧស្សាហកម្ម ធ្លាក់ចុះ ៩២% ពី ៣៩៣លានដុល្លារ មកត្រឹម ៣១លានដុល្លារ រីឯវិនិយោគវិស័យកសិកម្មកើនពី ២លានដុល្លារ ដល់ ១២៧លានដុល្លារ។ វិនិយោគវិស័យសេវាកម្មក៏កើនបាន ៩,៦% ដែរ ពី ៥៣លានដុល្លារ ដល់ ៥៨លានដុល្លារ។

Fixed asset approvals for private investment during January–February 2006 were USD216 m, 52 percent lower than in the same period a year ago. Industrial sector investment dropped by 92 percent to USD31 m from USD393 m, while agricultural investment rose by USD127 m from USD2 m. Investment in services also increased, by 9.6 percent, to USD58 m from USD53 m.

**Fixed Asset Private Investment: Approvals 2003 Q3–2006 Q1***




** Up to February 2006.*
*Including expansion projects.*
Source: Council for the Development of Cambodia

នៅត្រីមាសទី១ ២00៦ ភ្ញៀវបរទេសមកដល់កម្ពុជាមាន ៤៥៧.៣0៥នាក់ ឬ ច្រើនជាងត្រីមាសមុន ១0% ។ គិតតាមត្រីមាស ភ្ញៀវបរទេសមកតាមផ្លូវអាកាស មានប្រហែល ៦0% នៃភ្ញៀវសរុប ឬ ២៧៥.៣៩១នាក់ (កើន ៩,0% ធៀបនឹងត្រីមាសមុន) ។ ភ្ញៀវបរទេសចូលតាមផ្លូវគោក និងផ្លូវទឹកក៏កើន ១១% ដែរ ដល់ ១៨១.៩១៤នាក់ ។ ធៀបនឹងត្រីមាសទី១ ឆ្នាំមុន ភ្ញៀវបរទេសសរុប កើនបាន ២0%។

In the first quarter of 2006, 457,305 foreign visitors arrived in Cambodia, 10 percent more than in the preceding quarter. Quarterly arrivals by air accounted for around 60 percent of total visitors, reaching 275,391 (an increase of 9.0 percent from the previous quarter). During the same period, arrivals by land and water also increased, by 11 percent, to 181,914. Compared to the first quarter last year, the total of foreign visitors was up by 20 percent, a 19 percent rise in the number of visitors arriving by air and a 22 percent increase in arrivals by land and water.

**Foreign Visitor Arrivals 2003 Q3–2006 Q1**




*Note: Latest data available are for March 2006.*
Source: Ministry of Tourism

តំលៃគំរោងសាងសង់ដែលអនុម័តនៅភ្នំពេញ បានធ្លាក់ចុះអស់៤ត្រីមាសជាប់គ្នា។ នៅត្រីមាសទី១ ២00៦ វាធ្លាក់ចុះ ៦,២% ធៀបនឹងត្រីមាសមុនមកត្រឹម ៦៧លានដុល្លារ។ ក្នុងពេលជាមួយគ្នា សំណង់ផ្ទះល្វែង និងសំណង់ដទៃទៀត ធ្លាក់ចុះ ១២% មកត្រឹម ៤0លានដុល្លារ និង ១៩% មកត្រឹម ១៧លានដុល្លារ រៀងគ្នា ។ ប៉ុន្តែ តំលៃសំណង់ភូមិគ្រឹះ និងផ្ទះបានអនុម័តបានកើនជិតមួយជាពីរក្នុងកំឡុងពេលនេះ។

The value of construction project approvals in Phnom Penh has declined for four consecutive quarters. It decreased by 6.2 percent to USD67 m in 2006 Q1, compared to the preceding quarter. In the quarter, flat and other construction activities declined 12 percent to USD40 m and 19 percent to USD17 m, respectively. However, the value of villa and house construction project approvals almost doubled.

**Construction Project Approvals: Phnom Penh 2003 Q3–2006 Q1**




*Note: Latest data available are for March 2006.*
Source: Department of Cadastre and Geography, Phnom Penh Municipality.

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

នៅខែឧសភា ២០០៦ ថ្លៃម៉ាស៊ូតនៅភ្នំពេញ កើនបាន ៧,០% ធៀបនឹងខែមុន និងខ្ពស់ជាងកំនើនថ្លៃសាំង (៣,៦%) ។ ថ្លៃម៉ាស៊ូត ជាមធ្យមគឺ ៣១៣០រៀល/លីត្រ ដោយកើនពី ២៩៣០រៀល/លីត្រ នៅខែមេសា ។ នៅខែឧសភា សាំងលក់ថ្លៃ ៣៩៤០រៀល/លីត្រ ដោយកើនពី ៣៨០០រៀល/លីត្រ នៅខែមេសា។

In May, diesel prices in Phnom Penh rose by 7.0 percent compared to the preceding month, a faster rate than the rise in gasoline (3.6 percent). The price of diesel averaged 3130 riels/litre in May, up from 2930 riels/litre in April. In May, one litre of gasoline cost 3940 riels, up from 3800 riels in April.

**Gasoline and Diesel Prices: Phnom Penh**
**March 2005–May 2006**




Sources: CDRI and National Institute of Statistics

នៅខែមេសា ២០០៦ ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ កើនបាន ០,៣% បន្ទាប់ពីធ្លាក់ចុះបន្តិចអស់ពីរខែជាប់គ្នា។ ថ្លៃម្ហូបអាហារ កើនបាន ០,២% គឺទាបជាង កំនើន ២,៨% នៅខែដូចគ្នា ឆ្នាំមុន ។ ចំណាយលើការដឹកជញ្ជូន និងទូរគមនាគមន៏ កើនបាន ១,៦% ដែលជាអត្រាខ្ពស់ជាងនៅខែមេសា ឆ្នាំមុន (១,០%) ។

After a slight fall for two consecutive months, consumer prices in Phnom Penh rose by 0.3 percent in April. Food prices rose 0.2 percent, compared with 2.8 percent in the same month last year. The cost of transportation and communication rose 1.6 percent, more than in April a year earlier (1.0 percent).

**Consumer Price Index**
(July–December 2000=100)




*Note: Latest data available are for March 2006.*
Source: National Institute of Statistics

អង្កេតប្រចាំត្រីមាស ចំពោះកម្មករងាយរងគ្រោះនៅភ្នំពេញ ធ្វើឡើងដោយ វិបសអ បង្ហាញថា ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប និងអ្នកធាក់ស៊ីក្លូ បានធ្លាក់ចុះ នៅខែកុម្ភៈ ២០០៦ ធៀបនឹងពេលដូចគ្នា ឆ្នាំមុន ។ ចំណូលរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះអស់ ២៥% មកត្រឹម ៨៩០០រៀល/១ថ្ងៃ ហើយចំណូលរបស់អ្នកធាក់ស៊ីក្លូ ធ្លាក់ចុះ ៧,៧% មកត្រឹម ៧៩០០រៀល /១ថ្ងៃ ។ ប៉ុន្តែ ចំណូលរបស់កម្មករសំណង់គ្មានជំនាញ កើនបន្តិចបាន ៤,០% ដល់ ៦០០០រៀល/១ថ្ងៃ។

CDRI's quarterly survey of vulnerable workers in Phnom Penh found that real daily earnings of motorcycle-taxi drivers and cyclo drivers in February declined, compared to the same time one year earlier, while earnings of unskilled construction workers increased. Motorcycle-taxi drivers' earnings fell by 25 percent to KHR8900 per day, and earnings of cyclo drivers decreased by 7.7 percent to KHR7900 per day. Unskilled construction workers increased their earnings by 4.0 percent, to KHR6000 per day.

**Vulnerable Workers: Phnom Penh**
**Real Daily Average Earnings**
**August 2003–February 2006**




* *Revised*
Source: CDRI

# ស្ថានភាពអត្រាប្តូរប្រាក់ និង រូបិយវត្ថុ

# Exchange Rates and Monetary Developments

នៅខែឧសភា ២០០៦ ប្រាក់រៀលប្តូរបាន ៤.១១០រៀល/ដុល្លារ ដោយធ្លាក់ថ្លៃអស់ ០,៥% ធៀបនឹងខែមុន និងធ្លាក់អស់ ០,៧% ធៀបនឹងខែឧសភាឆ្នាំមុន ។

The riel traded at 4110 to the US dollar in May, a depreciation of 0.5 percent from the previous month and 0.7 percent from May last year.

**Riels per US Dollar**
**March 2005 – May 2006**




Sources: National Bank of Cambodia and CDRI

នៅខែឧសភា ២០០៦ ប្រាក់រៀលធ្លាក់ថ្លៃទល់នឹងប្រាក់បាតថៃ អស់ ២% គឺស្រដៀងគ្នានឹងខែមុន ។ វាប្តូរបាន ១០៩រៀល/បាត ធៀបនឹង ១០៧រៀល/បាត នៅខែមេសា ។ ប្រាក់រៀលស្ទើរតែមិនប្រែប្រួលទល់នឹងប្រាក់ដុងវៀតណាម ដោយប្តូរបាន ២៥រៀល/១០០ដុង។

The riel depreciated against the Thai baht in May by a similar amount (2 percent) to the preceding month. It traded at around 109 riels/baht in May, depreciating from 107 in April. The riel remained mostly unchanged against the Vietnamese dong, trading at around 25 riels per 100 VND.

**Riels against THB and VND**
**March 2005–May 2006**




Source: CDRI

នៅចុងខែមីនា ២០០៦ រូបិយវត្ថុទូទៅរបស់ប្រព័ន្ធធនាគារ កើនដល់ ៥៧១១ពាន់លានរៀល រឺ៣,៧% ខ្ពស់ជាងនៅចុងខែកុម្ភៈ ។ កំណើននេះជាសំខាន់បណ្តាលពីកំណើនបញ្ញើប្រាក់រៀលក្នុងធនាគារ (៥,០%) និងបញ្ញើរូបិយវត្ថុបរទេស (៤,០%)។

The liquidity of the banking system at the end of March 2006 rose to KHR5711 bn, 3.7 percent more than at the end of February. This increase was led by rises in riel bank deposits (5.0 percent) and in foreign currency deposits (4.0 percent).

**Banking System Liquidity**
**January 2005–March 2006**




* *Revised*
*Note: Latest data available are for March 2006.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

នៅត្រីមាសទី១ ២០០៦ កម្ពុជា នាំចេញសរុប ៦០៣លានដុល្លារ រឺធ្លាក់ចុះ ៦,៥% ធៀបនឹងត្រីមាសមុន ។ ការនាំចេញសំលៀកបំពាក់ កៅស៊ូ និង ត្រី ធ្លាក់ចុះទាំងអស់នៅកំឡុងពេលនេះ ។ ការនាំចេញសំលៀកបំពាក់ ធ្លាក់ចុះ ៥,៤% មកត្រឹម ៥៦៩លានដុល្លារ ឯការនាំចេញកៅស៊ូ ចុះអស់ ៤២% មកត្រឹម ៧,៨លានដុល្លារ ហើយការនាំចេញត្រី ចុះអស់ ៧១% មកត្រឹម ២លានដុល្លារ ។ ធៀបនឹងត្រីមាសទី១ ២០០៥ ការនាំចេញសរុបកើនបាន ៣០% ។

Cambodian exports totalled USD603 m in 2006 Q1, a decrease of 6.5 percent from the preceding quarter. Exports of garments, rubber and fish all declined. Garment exports dropped by 5.4 percent to USD569 m, rubber by 42 percent to USD7.8 m, and fish by 71 percent to USD2 m. Compared to 2005 Q1, total exports were up by 30 percent.

**Cambodia: Main Exports**
**2003 Q3 – 2006 Q1**




*Note: Latest data available are for March 2006.*
Source: Customs and Excise Department

នៅត្រីមាសទី១ ២០០៦ ការនាំចូលស៊ីម៉ង់ត៍និងដែក កើនឡើងធៀបនឹងត្រីមាសទី៤ ២០០៥ ។ ការនាំចូលស៊ីម៉ង់ត៍ កើនបាន ៥៦% ដល់ ៦៥ពាន់លានរៀល ហើយការនាំចូលដែក កើនបាន ៨៩% ដល់ ៥១ពាន់លានរៀល ។ បើធៀបនឹងត្រីមាសទី១ ២០០៥ ការនាំចូលស៊ីម៉ង់ត៍ និងដែក មានកំណើន ៤៨% និង ៣២% រៀងគ្នា ។

Imports of cement and steel rose in 2006 Q1, compared to 2005 Q4. Cement imports rose by 56 percent to KHR65 bn, and steel imports increased by 89 percent to KHR51 bn. Compared to 2005 Q1, imports of cement and steel also increased, by 48 percent and 32 percent respectively.

**Construction Material Imports**
**2004 Q1– 2006 Q1**




*Note: Latest data available are for March 2006.*
Source: Control Office, Customs and Excise Department

នៅត្រីមាសទី១ ២០០៦ ការនាំចូលប្រេងសាំង និងម៉ាស៊ូត មានចំនួន ៤៤ពាន់លានរៀល និង១៣៣ពាន់លានរៀល រៀងគ្នា ។ ធៀបនឹងត្រីមាសមុន ការនាំចូលប្រេងម៉ាស៊ូត កើនឡើងបាន ៥១% រីឯការនាំចូលប្រេងសាំងធ្លាក់ចុះបន្តិចអស់ ០,៤% ។ ប៉ុន្តែ ករិតនេះ នៅតែខ្ពស់ជាងតួលេខកាលពីត្រីមាសដូចគ្នា ឆ្នាំមុន ដល់ទៅ ៥២% និង ៧,១% រៀងគ្នា ។

In the first quarter, KHR133 bn of diesel and KHR44 bn of gasoline were imported. Compared to the preceding quarter, the value of diesel imports increased by 51 percent, while gasoline imports declined by 0.4 percent. However, both were higher than their value in the same quarter last year, by 52 percent and 7.1 percent, respectively.

**Petroleum Product Imports**
**2004 Q1–2006 Q1**




*Note: Latest data available are for March 2006.*
Source: Control Office, Customs and Excise Department

# ប្រភព និងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

នៅកំឡុងឆ្នាំ ១៩៩២-២០០៥ កម្ពុជាទទួលបានការបើកផ្ដល់ជំនួយអភិវឌ្ឍន៍បរទេសសរុប ៦២៦៧លានដុល្លារ ។ កិច្ចសហប្រតិបត្តិការបច្ចេកទេសបើកចំហ សំដៅដល់ជំនួយដែលមិនជាប់ទាក់ទិននឹងគំរោងវិនិយោគណាមួយឡើយ ។

During the period 1992–2005, Cambodia received a total of USD6267 m of foreign development assistance. Free-standing technical cooperation refers to assistance not related to any investment projects.

**External Development Assistance: Disbursements 1992–2005**




Source: Council for the Development of Cambodia

នៅឆ្នាំ២០០៥ នៅក្នុងជំនួយអភិវឌ្ឍន៍ក្រៅប្រទេសសរុប (៥២៥លានដុល្លារ) គឺមានប្រហែល ៣៥% រឺ ១៨២លានដុល្លារ សំរាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសបើកចំហ ។ ធៀបនឹងឆ្នាំមុន វាកើនបន្តិចបាន ៣,០% ។

Of total external development assistance in 2005 (USD525 m), about 35 percent, or USD182 m, was for free-standing technical cooperation. This was an increase from the preceding year of 3.0 percent.

**External Development Assistance**
**Free-Standing Technical Cooperation: 1992–2005**




** Provisional.*
Source: Council for the Development of Cambodia

នៅឆ្នាំ ២០០៥ ថវិកាបើកផ្ដល់សំរាប់ជួយដល់គំរោងវិនិយោគ មាន ២៦១លានដុល្លារ រឺ ជិតដល់ ៥០% នៃការបើកផ្ដល់សរុបនៅឆ្នាំ ២០០៥ ។ វាកើនបានតែបន្តិចត្រឹម ០,២% ធៀបនឹងឆ្នាំ ២០០៤ ។

In 2005, disbursements for investment project assistance amounted to USD261 m, nearly 50 percent of 2005’s total disbursements, but an increase of only 0.2 percent compared to 2004.

**External Development Assistance**
**Investment Project Assistance: 1992–2005**




** Provisional.*
Source: Council for the Development of Cambodia

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែមករា ២០០៦ ដំណើរការថវិកាចរន្ត មានអតិរេកថវិកា ១៦៧ពាន់លានរៀល ធៀបនឹងឱនភាពថវិកា ១៤២ពាន់លានរៀល នៅខែធ្នូ ២០០៥។ ប៉ុន្តែ អតិរេកនេះ មានកំរិតទាបជាង នៅខែដូចគ្នា ឆ្នាំមុនបន្តិច (អតិរេក ១៦៨ពាន់លានរៀល)។

In January, current budget operations showed a surplus of KHR167 bn, compared with a deficit of KHR142 bn in December. This surplus was slightly lower than in the same month last year (KHR168 bn).

**Current Budget Operations**
**November 2004–January 2006**




*Note: Provisional for 2004–2006.*
*Latest data available are for January 2006.*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែមករា ២០០៦ ចំណូលថវិកាចរន្តមានចំនួន ១៩២ពាន់លានរៀល រឺ ៤៥% តិចជាងខែមុន ប៉ុន្តែត្រូវជា ៧,៦%ច្រើនជាងខែមករា ឆ្នាំមុន ។ ក្នុងនេះចំណូលពីពន្ធក្នុងស្រុកកើន ២១% ធៀបនឹងខែមករា ឆ្នាំមុន ដល់ ៥០ពាន់លានរៀល, ចំណូលមិនមែនពន្ធកើន ១៤% ដល់ ៤១ពាន់លានរៀល ឯចំណូលពន្ធនាំចេញនាំចូល ធ្លាក់ចុះ ០,៤% ដល់ ១០១ពាន់លានរៀល ។

Current revenue amounted to KHR192 bn in January, a decrease of 45 percent from the preceding month, but an increase of 7.6 percent from the same month a year earlier. Domestic tax receipts rose by 21 percent over January 2005, to KHR50 bn. Non-tax revenue increased 14 percent during the same period, to KHR41 bn, while revenue from import and export taxes decreased by 0.4 percent to KHR101 bn.

**Current Budget Revenue**
**November 2004–January 2006**




*Note: Provisional for 2004–2006.*
*Latest data available are for January 2006.*
Source: *Monthly Bulletin of Statistics* (MEF)

ចំនាយថវិកាចរន្តនៅខែមករា ២០០៦ គឺ ២៥ពាន់លានរៀល រឺ ៩៥% តិចជាងនៅខែមុន។ ធៀបនឹងខែមករា ២០០៥ វាកើនច្រើនជាងមួយជាពីរ ដោយសារជាសំខាន់ កំនើនចំណាយការពារជាតិនិងសន្តិសុខ (ពីសូន្យ ដល់ ៦,៥ពាន់លានរៀល) និង ចំណាយរដ្ឋបាលទូទៅ (ពី ២,៣ពាន់លានរៀល ដល់ ១១,៥ពាន់លានរៀល) ។ ចំនាយលើរដ្ឋបាលសង្គមកិច្ច ថយចុះ ៩៥% (ពី ៦,៤ពាន់លានរៀល ដល់ ០,៣ពាន់លានរៀល) ។

Current expenditure of the government in January was KHR25 bn, 95 percent less than in the previous month. Compared to January 2005, however, it more than doubled, mainly due to increased spending on defence and security (from nil to KHR6.5 bn) and on general administration (from KHR2.3 bn to KHR11.5 bn). Expenditure on social administration dropped by 95 percent, from KHR6.4 bn to KHR0.3 bn.

**Current Budget Expenditure**
**November 2004–January 2006**




*Note: Provisional for 2004–2006.*
*Latest data available are for January 2006.*
Source: *Monthly Bulletin of Statistics* (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែមីនា ការនាំចេញទំនិញរបស់ US តំបន់អឺរ៉ូ និងជប៉ុនកើនឡើង ។ ការនាំចេញរបស់US កើនបាន ២០% ធៀបនឹងខែមុន ដល់ ៨២ពាន់លានដុល្លារ ។ កំណើនការនាំចេញទំនិញ ភាគច្រើនបណ្ដាលមកពីកំនើនគ្រឿងផ្គត់ផ្គង់និងសំភារៈឧស្សាហកម្ម និងទំនិញមូលធន ។ ការនាំចេញទំនិញរបស់តំបន់អឺរ៉ូ កើនបាន ១២% ធៀបនឹងខែមុន ដល់ ១៤៥ពាន់លានដុល្លារ។ ការនាំចេញរបស់ជប៉ុនកើនបាន ១៦% ធៀបនឹងខែមុន ដល់ ៥៨ពាន់លានដុល្លារ។

In March, goods exports of the US, Eurozone and Japan increased. US exports rose by 20 percent from the previous month to USD82 bn. The increase in goods exports reflected increases in industrial supplies and materials and in capital goods. Eurozone goods exports rose by 12 percent from the previous month to USD145 bn. Japan's goods exports rose by 16 percent from the previous month to USD58 bn.

**Goods Exports: US, Eurozone and Japan**
(USD bn)




Sources: BEA, Eurostat and OECD

នៅខែមីនា ការនាំចេញទំនិញរបស់កូរ៉េខាងត្បូង កើន ១៣% ធៀបនឹងខែមុន ដល់ ២៧ពាន់លានដុល្លារ និងកើន ១២% ធៀបនឹងពេលដូចគ្នាឆ្នាំមុន។ នៅខែមីនា ការនាំចេញទំនិញរបស់តៃវ៉ាន់ កើន ១៤% ដល់ ១៨ពាន់លានដុល្លារ និងកើន ១២% ធៀបនឹងខែដូចគ្នា ឆ្នាំមុន ។

In March, goods exports of South Korea increased by 13 percent from the previous month to USD27 bn and by 12 percent from the same period last year. Taiwan's goods exports in March increased by 14 percent to USD18 bn and by 12 percent from the same month last year.

**Goods Exports: South Korea and Taiwan**
(USD bn)




Sources: National statistics departments of each country

នៅខែមីនា ម៉ាឡេស៊ី មានអតិរេកពាណិជ្ជកម្ម ២,៥ពាន់លានដុល្លារ ធៀបនឹង ២ពាន់លានដុល្លារ នៅខែកុម្ភៈ។ ការនាំចេញសរុប កើនបាន ២១% ដល់ ១៣ពាន់លានដុល្លារ រីឯ ការនាំចូលសរុប កើនបាន ២០% ដល់ ១១ពាន់លានដុល្លារ ។ ផលិតផលអគ្គិសនី និងអេឡិចត្រូនិក មានចំនួន ៤៨% នៃការនាំចេញសរុប ( ៦ពាន់លានដុល្លារ) ។

In March, Malaysia recorded a trade surplus of USD 2.5 bn, compared to USD 2 bn in February. Total exports increased by 21 percent to USD13 bn, while total imports rose by 20 percent to USD 11 bn. Electrical and electronic products account for 48 percent of total exports (USD 6 bn).

**Malaysia: External Trade**
(USD bn)




Source: Department of Statistics Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ជប៉ុន មានអតិផរណាសាជាថ្មីទៀត ។ ថ្លៃទំនិញប្រើប្រាស់ កើនឡើង ០,៣% ក្នុងរយៈ១ឆ្នាំដល់ចុងខែមីនា ។ ថ្លៃទំនិញសំខាន់ៗ លើកលែងតែម្ហូបស្រស់ កើន ០,៥% (កើន ៥ខែជាប់គ្នាមកហើយ)។ ពីខែកុម្ភៈ ដល់មីនា អតិផរណាទំនិញប្រើប្រាស់នៅអាមេរិក និងអឺរ៉ុប ធ្លាក់ចុះពី ៣,៦% ដល់ ៣,៤% និងពី២,៣% ដល់២,២% ដែលបណ្តាលជាសំខាន់ពី ការប្រែប្រួលថ្លៃថាមពល និងថ្លៃម្ហូបអាហារគ្មានកែច្នៃ។

Japan is again experiencing price inflation. Consumer prices rose by 0.3 percent in the year to March. According to *The Economist* core prices, excluding fresh food, rose by 0.5 percent, the fifth monthly increase in a row. During the same period, consumer inflation in the U.S and in the Eurozone decreased to 3.4 percent and 2.2 percent from 3.6 percent and 2.3 percent in February, respectively. This resulted mainly from changes in energy and unprocessed food prices.

**Inflation Rate: US, EU & Japan**

(percentage change over the previous year)




*Note: The latest data available are for March 2006.*

Sources: IMF and *Economist* (May 20th - 26th 2006)

នៅខែមីនា ថ្លៃទំនិញប្រើប្រាស់ទូទៅ នៅហុងកុង កើន ១,៨% ធៀបនឹងមួយឆ្នាំមុន និងកើន ១,៦% ធៀបនឹងខែកុម្ភៈ ។ រឿងនេះ បណ្តាលមកពីកំណើនថ្លៃឈ្នួលផ្ទះឯកជន និងថ្លៃអាហារទិញហូបក្រៅផ្ទះ ទោះបីជាមានការធ្លាក់ថ្លៃកញ្ចប់ខ្សែទស្សនកិច្ចក្តី ។ ក្នុងកំឡុងពេលដូចគ្នា អតិផរណាទំនិញប្រើប្រាស់ ធ្លាក់ចុះមកត្រឹម ០,៨% នៅចិន និង ២,០% នៅកូរ៉េខាងត្បូង ។

Hong Kong’s consumer prices rose by 1.8 percent in March compared to a year earlier, larger than 1.6 percent increase in February. This was attributable to increases in private housing rentals and the costs of meals bought away from home as well as a decline in charges for package tours. During the same period, consumer inflation slowed to 0.8 percent in China and eased to 2.0 percent in South Korea.

**Inflation Rate: China, Hong Kong & South Korea**

(percentage change over the previous year)




*Note: The latest data available are for March 2006.*

Sources: IMF and *Economist* (May 20th - 26th 2006)

នៅខែមីនា ២០០៦ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរីមានកំរិត ១,២% ខ្ពស់ជាងនៅខែដូចគ្នា ឆ្នាំមុន ។ រឿងនេះ បណ្តាលជាសំខាន់មកពីការឡើងថ្លៃម្ហូបអាហារ សំលៀកបំពាក់ ស្បែកជើង ផ្ទះ ការអប់រំ សំភារៈការិយាល័យ ការថែទាំសុខភាព និងលំហែកំសាន្ត ។ អតិផរណាក្នុងរយៈមួយឆ្នាំ មានកំរិត ៤,៨% នៅម៉ាឡេស៊ី និង ៥,៧% នៅថៃ។

Singapore's consumer price index in March 2006 was 1.2 percent higher compared to the same month a year earlier. This reflected higher costs of foodstuffs, clothing and footwear, housing, education and stationery, healthcare as well as recreation. Meanwhile, the year-on-year inflation rate was 4.8 percent in Malaysia and 5.7 percent in Thailand.

**Inflation Rate: Selected ASEAN Countries**

(percentage change over the previous year)




*Note: The latest data available are for March 2006.*

Sources: IMF and *Economist* (May 20th - 26th 2006)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rate in World Markets

នៅខែឧសភា ២០០៦ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុសំខាន់ៗ ដោយសារការវាយស្មានថា ធនាគារកណ្តាលអាមេរិកជិតបញ្ឈប់ការតំលើងការប្រាក់ ហើយធនាគារកណ្តាលឯទៀតឆ្លៀតពេលដែលប្រាក់អឺរ៉ូ និង យ៉េន ចុះថ្លៃ បានទិញវាទុក ដោយគិតថាវានឹងឡើងថ្លៃ ក្នុងឆ្នាំ ២០០៦ នេះ ។ ធៀបនឹងខែមេសា ដុល្លារអាមេរិកធ្លាក់ថ្លៃប្រហែល ៤% ទល់នឹង អឺរ៉ូ ដោយប្តូរបាន ០,៧៨អឺរ៉ូ/ដុល្លារ និងចុះថ្លៃ ៤,៥% ទល់នឹងប្រាក់យ៉េនជប៉ុន ដោយប្តូរបាន ១១១,៨យ៉េន/ដុល្លារ ។

In May 2006, the US dollar fell against major currencies on speculation that U.S Federal Reserve may soon stop raising interest rates, while other central banks took advantage of a drop in the euro and yen to buy those currencies, counting on continued gains in 2006. Against the euro, the USD exchanged at 0.78 EUR, a 4 percent depreciation from April. Against the Japanese yen, it traded at 111.8 JPY/USD, a 4.5 percent decline from the previous month.

### Euro and Japanese Yen Against the US Dollar




*Note: Data are up to 31 May 2006.*
Source: Federal Reserve Bank of New York

នៅខែឧសភា ២០០៦ ប្រាក់វ៉ុនកូរ៉េខាងត្បូងឡើងថ្លៃទល់នឹងដុល្លារUS ដល់ ៩៤១,០១វ៉ុន/ដុល្លារUS ( ៩៥២,៦០វ៉ុន/ដុល្លារUSនៅខែមុន) ។ ក្នុងកំឡុងពេលដូចគ្នា ដុល្លារហុងកុងឡើងថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៧៥ដុល្លារហុងកុង/ដុល្លារUS ។ ហុងកុងបានចងភ្ជាប់រូបិយវត្ថុរបស់ខ្លួនទៅនឹងដុល្លារUS ដោយទុកអោយវាឡើងចុះតែក្នុងក៏រិតពី ៧,៧៥ ទៅ ៧,៨៥ដុល្លារហុងកុង/ដុល្លារUS ។

In May 2006, the South Korean won advanced against the US dollar, climbing to 941.01 KRW/USD, up from 952.60 KRW/USD a month earlier. During the same period, the Hong Kong dollar slightly appreciated against its US counterpart trading at 7.75HKD/USD. Hong Kong has pegged its currency to the U.S dollar allowing trading in the range HKD 7.75 - 7.85.

### South Korean Won and Hong Kong Dollar Against US Dollar




*Note: Data are up to 31 May 2006.*
Source: Federal Reserve Bank of New York

នៅខែមេសា ២០០៦ ដុល្លារសិង្ហបុរីបន្តឡើងថ្លៃបាន ៦ខែជាប់ៗគ្នា ទល់នឹងដុល្លារUS ដោយឡើងដល់ ១,៥៧៦ដុល្លារសឹង្ហបុរី/ដុល្លារUS ( ១,៦០១ ដុល្លារសិង្ហបុរី/ដុល្លារUS នៅខែមុន) ។ នៅខែនេះដែរ ប្រាក់បាតថៃនៅថេរទល់នឹងដុល្លារUS ដោយប្តូរបាន ៣៨,០០បាត/ដុល្លារUS ។ ដុល្លារUS ចាប់ផ្តើមធ្លាក់ចុះ បន្ទាប់ពីអាមេរិកបានអំពាវនាវជាច្រើនលើកឱ្យតំលើងថ្លៃរូបិយវត្ថុអាស៊ីខ្លាំងៗ និងឱ្យប្រាក់យាន់ចិនអាចឡើងចុះបានងាយជាងមុន ។

In April 2006, the Singapore dollar continued to strengthen for a sixth consecutive month against its US counterpart, climbing to 1.576 SGD/USD from 1.601 SGD/USD, in the previous month. Meanwhile, the Thai baht was flat against the US dollar, exchanging at 38.00 THB/USD. The dollar dropped after the U.S repeated calls for stronger Asian currencies and the need to make China’s yuan more flexible.

### Thai Baht and Singapore Dollar Against US Dollar




*Note: Data are up to 31 May 2006.*
*Source: Federal Reserve Bank of New York*

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែមេសា ២00៦ ថ្លៃអង្ករពិភពលោកបានកើនឡើងបន្តិច ។ សន្ទស្សន៍ថ្លៃអន្តរជាតិ កើនបន្តិចដល់ ១២៥,១ ពិន្ទុ ធៀបនឹង ១២៤,៩ ពិន្ទុ នៅខែមីនា។ នៅសហរដ្ឋអាមេរិក ថ្លៃនាំចេញកើនដល់ ៣៣៦ដុល្លារ/តោន ធៀបនឹង ៣៣១ដុល្លារ/តោន នៅខែមីនា ។ នៅថៃ ថ្លៃអង្ករក៏បានកើនបន្តិចដែរ ។ នៅខែមេសា អង្ករ Thai 100%B លក់ថ្លៃ ២៨0,៣0ដុល្លារ/តោន ដោយកើនពី ២៧៩,៨0ដុល្លារ/តោននៅខែមីនា ។

In April 2006, world rice prices increased slightly. The international price index (IPO) went up slightly to 125.1 against 124.9 in March. In the United States, the export prices increased to USD 336 per tonne, against USD 331 per tonne in March. In Thailand, prices also rose slightly. In April, Thai 100%B was USD 280.30 per tonne, up from USD 279.80 per tonne in March.

**International Prices Index and Export Rice Prices**
(USD/tonne FOB)




Source: Osiriz/InfoArroz and InterRice.

នៅខែឧសភា ថ្លៃសណ្តែកសៀង និងពោតកើនឡើង។ សណ្តែកសៀង លក់ថ្លៃ ២0៩ដុល្លារ/តោន គឺកើនពី ២0៣ដុល្លារ/តោន នៅខែមេសា។ ពោតលក់ថ្លៃ ១0១ដុល្លារ/តោន ដោយកើនពី ៩៨ដុល្លារ/តោន នៅខែមេសា ។ ប្រេងឆាធ្លាក់ថ្លៃបន្តិច ពី ៣៩៩ដុល្លារ/តោន នៅខែមីនា មកត្រឹម ៣៩៨ដុល្លារ/តោន នៅខែមេសា ។

In May, the prices of soybeans and maize increased. Soybeans sold at USD 209 per tonne, up from USD 203 per tonne in April. Maize sold at USD 101 per tonne, up from USD 98 per tonne in April. In April, palm oil went down slightly, from USD 399 per tonne in March to USD398 per tonne.

**International Prices of Soybean, Maize and Palm Oil** (USD/tonne FOB)




Source: Food and Agriculture Organisation (FAO)

នៅខែឧសភា ថ្លៃប្រេងឆៅនៅថេរ ហើយថ្លៃប្រេងសាំងធ្លាក់ចុះ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៦៦ដុល្លារ/ធុង ធៀបនឹង ៦៥ដុល្លារ/ធុង នៅខែមេសា។ ប្រេងសាំងធម្មតា ( អុកតាន ៨៧) នៅ US Gulf Coast ធ្លាក់ចុះ ៥,៦% ដោយលក់ថ្លៃ ៥៣,៨សេន/លីត្រ ធៀបនឹង ៥៧,0សេន/លីត្រ នៅខែមេសា ។

In May, the price of crude oil was stable, while the price of gasoline went down. The OPEC spot price of crude oil was USD 66 per barrel, against USD 65 per barrel in April. Regular gasoline (87 octane) price at the US Gulf Coast declined by 5.6 percent, selling at 53.8 cents per litre compared to 57.0 cents per litre in April.

**Prices of Crude Oil and Gasoline**




***Note:*** *Data are up to 31 May 2006.*
*Source: Energy Information Administration*

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

**ផលិតផលវៀតណាមលក់ដាច់ល្អនៅកម្ពុជា:** នាបច្ចុប្បន្ន អតិថិជនកាន់តែងាយស្រួលក្នុងការរកទិញផលិតផលវៀតណាម នៅភ្នំពេញ ។ ផលិតផលវៀតណាមមានលក្ខណៈទាក់ទាញ ចំរុះបែប និងលក់ថោកជាងផលិតផលឯទៀត ។ តាមម្ចាស់តូបនៅផ្សារអូរឬស្សី ទំនិញវៀតណាមមានឈ្មោះល្បីដោយសារមានគុណភាពខ្ពស់ និងតំលៃថោក។ ក្រោយពីទទួលជោគជ័យថ្មីៗក្នុងការបង្ហាញផលិតផល អាជីវកម្មវៀតណាមកំពុងពង្រីកបណ្តាញចែកចាយនៅកម្ពុជា ។ តាមលោក Le Bien Cuong កុងស៊ុលពាណិជ្ជកម្មវៀតណាមនៅកម្ពុជា បរិមាណនាំចេញបានកើនឡើង ៤ដង ពី ១៣៣លានដុល្លារនៅឆ្នាំ២០០០ ដល់៥៣៦លានដុល្លារនៅឆ្នាំ២០០៥ ។

**កម្ពុជាអនុម័តផែនការអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំ លើកទី៣:** យុទ្ធសាស្រ្តផែនការអភិវឌ្ឍន៍ជាតិលើកទី ៣ របស់កម្ពុជា សំរាប់ឆ្នាំ២០០៦-២០១០ ត្រូវបានអនុម័តដោយសភាជាតិ ។ ផែនការ៥ឆ្នាំ ត្រូវបានអនុម័តនៅថ្ងៃទី ៩ ឧសភា ២០០៦ ។ ក្នុងផែនការនេះ រដ្ឋាភិបាលនឹងបង្កើន វិនិយោគសាធារណៈ និងឯកជន សំរាប់តំបន់ជនបទ សហគ្រាសតូចៗ សំដៅកាត់បន្ថយអត្រាគ្មានការងារធ្វើឱ្យនៅក្រោម ៤% និងអត្រាភាពក្រីក្រឱ្យនៅត្រឹម ២៤% នៅមុនដំណាច់ឆ្នាំ២០១០។ រដ្ឋមន្រ្តីក្រសួងផែនការ ឆាយ ថន លើកថា ដើម្បីសំរេចគោលដៅកំនត់ក្នុងផែនការ កម្ពុជាត្រូវការប្រាក់ ៣,៥ លានដុល្លារ ។ គោលដៅ រួមមាន ការកសាងហេដ្ឋារចនាសម្ព័ន្ធ អត្រាចុះឈ្មោះចូលរៀន ១០០% នៅបឋមសិក្សា ការបង្កើនទិន្នផលស្រូវប្រចាំឆ្នាំ ការកែលំអអនាម័យនៅជនបទ និងការកាត់បន្ថយអត្រាមរណៈកុមារ ។

***Vietnamese products sell well in Cambodia*** Consumers now have easier access to made-in-Viet Nam products in Phnom Penh. Viet Nam's products are more diverse, attractive and reasonably priced than others. Vietnamese goods, according to a store owner at OuRusSay Market, Phnom Penh, are famous for offering a wide range of high quality products at low prices. Following the success of a recent showroom, Vietnamese businesses are trying to widen their distribution network in Cambodia. According to Le Bien Cuong, Viet Nam's Trade Counselor in Cambodia, export turnover has increased four times from USD 133 m in 2000 to USD536 m in 2005. *(Cited from VNA 11th May 2006)*

***Cambodia enacts 3rd 5 year national development plan:*** Cambodia's 3rd national development planning strategy for 2006 to 2010 has been approved by the National Assembly. The 5-year plan was approved on 9 May 2006. Under the plan, the government will increase public and private investment in rural areas and smaller enterprises, lower Cambodia's unemployment rate to less than 4 percent and decrease the poverty rate to 24 percent by 2010. To realise the targets set by the plan, Cambodia needs USD 3.5 bn, according to Planning Minister Chhay Than. These targets include infrastructure construction, 100 percent enrollment in elementary schools, increasing the annual rice yield, improving sanitation condition in the rural areas and reducing infant mortality.

In this month's Flash Report we have made a number of changes to improve the usefulness of this publication to our readers. We welcome comments from our readers on these changes.

All quantities will be rounded to the nearest million or billion (i.e. 1000 million) as appropriate. Changes in quantities will be rounded to the nearest whole percent, except if the change is less than 10 percent, when it will be rounded to one decimal place.

A standard set of abbreviations, including international currency codes, will be used.

| | | |
|---|---|---|
| bn billion (i.e. 1000 million) | m million | |
| KHR riel | USD US dollar | EUR Euro |
| HKD Hong Kong dollar | JPY Japanese yen | KRW Korean won |
| SGD Singapore dollar | THB Thai baht | VND Vietnamese dong |